# សេះពាលាហនៅប្រាសាទនាគព័ន្ធ

ព្រះលោកេស្វរ គឺជាព្រះពោធិសត្វក្នុងព្រះពុទ្ធសាសនាមហាយាន។ ព្រះអង្គមិនព្រមត្រាស់ដឹងជាព្រះពុទ្ធទេ តែនៅចាំជួយមនុស្សសត្វឲ្យរួចផុតពីសេចក្ដីទុក្ខភ័យក្នុងស្ថានមនុស្ស និងស្ថាននរក។ យើងអាចឃើញភស្តុតាងដំបូងៗនៃការគោរពព្រះអង្គចាប់ពីស.វទី៧។ នៅស.វទី១០ ពុទ្ធសាសនាមហាយានចាប់ផ្ដើមរីកឡើងគួរកត់សម្គាល់ ជាពិសេសនៅចុងស.វទី១២ នៅពេលដែលព្រះបាទជ័យវរ្ម័ទី៧រាប់រកព្រះពុទ្ធសាសនាមហាយានកាន់តែខ្លាំងក្លា ជាពិសេសគឺព្រះពុទ្ធ លោកេស្វរ និងប្រាជ្ញាបារមីតា។ល។ អត្ថបទនេះនឹងពិនិត្យលើការបែងភាគរបស់ព្រះលោកេស្វរទៅជាសត្វសេះឈ្មោះ ពាលាហ។

សេះពាលាហធ្លាប់មានការសិក្សាល្អិតល្អន់ដោយលោក Victor Goloubew ចុះផ្សាយក្នុងព្រឹត្តិបត្រសាលាបារាំងចុងបូព៌ា ឆ្នាំ១៩២៧ ដោយលោកប្រៀបធៀបនឹងចម្លាក់បណ្ដាប្រទេសដែលទទួលវប្បធម៌ពីឥណ្ឌាទៀតផង។ ព្រមទាំងបានលើកយកគម្ពីរការណ្ឌវ្យុហសូត្រមកវិភាគជាដើម។ អត្ថបទនេះគ្រាន់ជាការបំពេញបន្ថែមលើអ្វីដែលមានស្រាប់ប៉ុណ្ណោះ ដោយពិនិត្យចម្លាក់នៅប្រាសាទនាគព័ន្ធ និងការប្រតិបត្តិទំនៀមសុំទឹកភ្លៀងនៅប្រាសាទនោះសម្រាប់ជាការពិចារណា។

គម្ពីរការណ្ឌវ្យុហសូត្រពាក់ព័ន្ធជាពិសេសនឹងព្រះលោកេស្វរ ត្បិតគម្ពីរនេះនិយាយអំពីភាពជាកំពូលនៃព្រះលោកេស្វរលើសទេពដទៃ សូម្បីទេពធំៗនៃព្រហ្មញ្ញសាសនាក៏ក្នុងគម្ពីរនោះនិយាយថាកើតចេញពីរាងកាយរបស់ព្រះលោកេស្វរដែរ។ លើសពីនោះគម្ពីរក៏មាននិយាយអំពីការជួយសង្គ្រោះយក្ស មនុស្ស និងប្រេតពីនរកអវិចីទៅកើតថ្មីជាព្រះពោធិសត្វនៅស្ថានសួគ៌ឈ្មោះសុខាវត្តី (ជាស្ថានសួគ៌នៅទិសខាងលិច)។ គម្ពីរនេះទំនងជាតាក់តែងឡើងនៅមុនស.វ.ទី៧នៃគ.ស។[1]

ភស្តុតាងមួយចំនួនបង្ហាញថា ខ្មែរសម័យបុរាណក៏ស្គាល់គម្ពីរនេះដែរ គឺសិលាចារឹកដែលគេមិនស្គាល់ប្រភព តែគេដឹងថានៅស.វទី១០ លេខរៀង K.1154 ចារលើសន្ទឹកម្ខាងទៀតនៃរូបចម្លាក់ព្រះលោកេស្វរ ដែលមានពាក្យ « (...) ឱំ មណិបទ្មេ ហុំ (...) »។[2] នេះគឺជា

[1] Studholm 2002: 12
[2] Skilling, 2003: 18

ពាក្យសូត្រសម្រាប់រំឭកដល់ព្រះលោកេស្វរដែលមាននិយាយក្នុងគម្ពីរនោះ។ ក្រៅពីនេះ សិលាចារឹកដីក្រែង (K.417)មានចុះកាលបរិច្ឆេទ៩៧០នៃគ.ស.ក៏មានរៀបរាប់ដែរថា ព្រះលោកេស្វរយាងចុះទៅសង្គ្រោះសត្វនរកពីទារុណកម្មផ្សេងៗក្នុងនរកអវីចី។[3] សេចក្តីត្រង់នេះក៏មាននិយាយក្នុងគម្ពីរនោះដែរ បានសេចក្តីថាភស្តុតាងទាំង២ស្តែងឲ្យឃើញច្បាស់ពីវត្តមានរបស់គម្ពីរនៅក្នុងសង្គមខ្មែរបុរាណ។ នេះពុំទាន់និយាយដល់ចម្លាក់មួយចំនួនទៀតក្នុងរាជ្យព្រះបាទជ័យវម៌្មទី៧ផងទេ។

ក្នុងគម្ពីរនេះនិយាយអំពីការសង្គ្រោះព្រះពោធិសត្វព្រះនាមសិង្ហាការាជាថា៖

ព្រះពោធិសត្វព្រះនាម សិង្ហាលារាជា និងនាយសំពៅ៥០០នាក់ធ្វើដំណើរទៅកោះសិង្ហាលា តែត្រូវខ្យល់ព្យុះវាយទូកបាក់ជាកំណាត់ ទៅទើលើកោះសិង្ហាលាដែលមានសុទ្ធតែយក្សីប្រែកាឡាខ្លួនជាស្រីស្អាត។ នាយសំពៅទាំងនោះកាលបើឃើញស្រីស្អាត រើសជាប្រពន្ធម្នាក់មួយក៏លែងចង់ត្រឡប់ទៅស្រុកវិញ។ លុះដល់ថ្ងៃមួយ នាយសំពៅដឹងថាពួកនារីៗដែលបម្រើខ្លួនទាំងនោះគឺជាយក្សីប្លែងខ្លួន ដើម្បីចាប់ស៊ីនាយសំពៅម្តងមួយៗរាល់យប់ ក៏នាំគ្នារិះរកវិធីរត់រកប្រាស់អាយុ។ ពេលនោះហើយ ព្រះលោកេស្វរប្រែកាឡាជាសត្វសេះមកសង្គ្រោះ ហោះនាំយកនាយសំពៅទៅជួបជុំគ្រួសារវិញ តែផ្តាំថា មិនត្រូវងាកក្រោយទេ។ បើមិនដូច្នោះទេនឹងធ្លាក់មកដីកើតជាចំណីពួកយក្សីវិញពុំខាន។[4]



រូបទី១

[3] Cœdès, 1942: 50
[4] Studholm 2002: 135-136

អត្ថបទដោយ៖ អ៊ូ គង្គា

## <u>អត្ថបទ៖ សេះពលាហនៅប្រាសាទនាគព័ន្ធ</u>

រឿងនេះ ខ្មែរបុរាណស្គាល់យ៉ាងប្រាកដ ហើយថែមចារក្នុងសិលាចារឹក និងឆ្លាក់ជាចម្លាក់ទៀតផង។ នៅប្រាសាទនាគព័ន្ធមានចម្លាក់មនុស្សតោងសេះដែលលើកជើង២ខាងមុខដូចកំពុងប្រុងប្រៀងហោះចេញឆ្ពោះទៅប្រាសាទនាគព័ន្ធ (រូបទី១)។ ចម្លាក់នោះខូចខាតដោយអន្ទើ តែយើងនៅអាចកត់សម្គាល់រូបមនុស្សទាំងនោះគឺថា ខ្លះអោបកសេះជាប់ ខ្លះចាប់តោងខ្លួនសេះជុំវិញរហូតដល់កន្ទុយផង។ ខ្លះទៀតឃើញថារបូតដៃធ្លាក់ចុះមកវិញក៏មាន ត្បិតនៅមិនអស់អាល័យរូបសម្រស់យក្សីក្លែងខ្លួននៅលើកោះ (រូបទី២)។ នៅលើខ្នងសេះក៏អាចមានរូបដែរ តែសព្វថ្ងៃមិនឃើញសល់ទេ ឃើញតែស្នាមរន្ធ៤ជ្រុងនៅចំពីលើខ្នងសេះ (រូបទី៣)។ ចំនួនចម្លាក់មនុស្សមិនដល់៥០០នាក់ទេដែលកំពុងតោងសេះកាយវិការប្រុងបោះពួយហោះ។ ទឹកស្រះនាគព័ន្ធពេលនេះហាក់ដូចជាមហាសមុទ្រនៃវដ្តសង្សារ ហើយព្រះលោកេស្វរក្លែងខ្លួនមកជួយរំដោះឲ្យផុតចេញពីវដ្តសង្សារនៃទុក្ខសោកភ័យព្រួយទាំងពួងបានទៅដល់ក្តីសុខក្សេមក្សាន្ត តែក៏ប្រាប់ឲ្យហើយដែរថាអាស្រ័យលើខ្លួនយើងដែរថា ចង់បានទុក្ខសោកភ័យព្រួយ ឬរួចផុតពីអស់ពីវដ្តសង្សារ។



រូបទី២



រូបទី៣

សិលាចារឹកប្រាសាទភិមានអាកាស (K.485) ចារជាភាសាសំស្ក្រឹតក្នុងស.វ.ទី១២រៀបរាប់នៅល្បះទី៣ថា «ព្រះលោកេស្វរដែលមើលថែរក្សាភាពត្រឹមត្រូវនៃពិភពលោក យកពិភពលោកដាក់ក្នុង (-អក្សររលុប-) ដែលសេះវាលាហកជះពន្លឺអំណាចចែងចាំងសង្គ្រោះអ្នកដើរសំពៅតាមសមុទ្រឲ្យត្រលប់មកវិញ---»។[5] ការវិវឌ្ឍពីអក្សរ«វ» ទៅជា«ព»គឺជារឿងធម្មតាដែលគេប្រទះឃើញក្នុងសិលាចារឹកជាច្រើន។ តាមរយៈសិលាចារឹកនេះហាក់បង្ហាញកាន់តែច្បាស់មួយកម្រិតទៀតថាខ្មែរសម័យនោះស្គាល់គម្ពីរទេវកថាព្រះពោធិសត្វប្រែកាឡាជាសេះហោះទៅជួយសង្គ្រោះមនុស្សដែលកំពុងជួបអាសន្ន ដូចបាននិយាយពីខាងលើជាពុំខាន។

---

[5] Finot, 1925: 385

អត្ថបទដោយ៖ អ៊ូ គង្គា

## *អត្ថបទ៖ សេះពលាហនៅប្រាសាទនាគព័ន្ធ*

នៅប្រាសាទនាគព័ន្ធសព្វថ្ងៃមានអ្នកភូមិមកពីភូមិលាងដៃ ភូមិភ្នង់ ភូមិសំរោងជាដើម ចំណាំធ្វើបុណ្យសុំទឹកភ្លៀងនៅដើមខែវស្សា។ ជួនគេហៅពិធីសុំទឹកភ្លៀងដូច្នេះមែន តែជួនកាលទៀតហៅ «ចាក់ត្រពោករាហូ»។ ហៅបែបនេះ ព្រោះថានៅកិច្ចចុងក្រោយបង្អស់ គេហែប្រទក្សិណ៣ជុំជុំវិញស្រះកណ្តាល ហើយចាក់ទឹកចូលរុន្ធតូចៗឲ្យទឹកហូរតាមទបេញមកក្រៅតាមមាត់ចម្លាក់នៃស្រះទាំង៤ ដូចក្នុងរូបទី៤។[6] ក្នុងចំណោមរូបទាំង៤រូបខាងកើតជារូបមនុស្ស ដែលអ្នកស្រុកហៅថា«រាហូ» (រូបទី៥)។ ក៏ប៉ុន្តែនៅល្ងាចថ្ងៃទី១នៃពិធីសុំទឹកភ្លៀងនោះមានកិច្ចសំខាន់មួយទៀតពាក់ព័ន្ធនឹងរូបចម្លាក់នេះដែរគឺ បញ្ចូលរូបអ្នកតា។ អ្នកតាដែលគេអញ្ជើញគឺមកជុំវិញប្រាសាទនាគព័ន្ធ ហើយក្នុងនោះក៏មានអ្នកតារាហូនេះដែរ ដ្បិតអ្នកស្រុកត្រូវការប្រាស្រ័យទាក់ទងឲ្យជួយកុំឲ្យមានខ្យល់ខ្លាំង (រូបទី៦)។ គេជឿទៀតថា បើរាហូនោះផ្លុំចេញជាខ្យល់ខ្លាំងពេកអាចបង្កជាព្យុះបោកបក់ភូមិដ្ឋានអ្នកស្រុកទៅវិញ។ អ្នកតាមួយទៀតគឺ ស្តេចកុជង្គនាគដែលនៅព័ន្ធជុំវិញជណ្តើរប្រាសាទនោះផ្ទាល់ (មើលរូបទី១ម្តងទៀត)។



រូបទី៤



រូបទី៥

[6] សាម ច័ន្ទរី: ២០០៩-១០។

អត្ថបទដោយ៖ អ៊ូ គង្គា



*រូបទី៦*

*ឥលូវសូមយើងត្រឡប់ទៅមើលសេះពាលាហវិញ។ នៅពេលក្រោយមក ខ្មែរហាក់ដូចជាលែងស្គាល់ថា ពាលាហគឺជា សេះ។ វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត ពន្យល់ពាក្យ «ពាលាហ»ថា «មេឃ; ពពក, ពពកខាប់; ភ្លៀង ។ ទេវតាអ្នកបណ្ដាលឲ្យកើតភ្លៀង, ឲ្យកើតខ្យល់; វស្សវលាហក ( វ័ស-ស:–) វលាហកបណ្ដាលឲ្យធ្លាក់ភ្លៀង; វាតវលាហក ( វាត:– ) វលាហកបណ្ដាលឲ្យមានខ្យល់ ។ សេះ, ច្រើនហៅថា សេះវលាហក»។ តាមពិតសេចក្តីពន្យល់នេះទំនងយកចេញពីគម្ពីរពុទ្ធសាសនាណាមួយ។ ឧទាហរណ៍គម្ពីរត្រៃភូមិដែលតាក់តែងតាមព្រះរាជបញ្ជារបស់ព្រះបាទអង្គឌួងមាននិយាយយោងលើពាលាហសូត្រថា ពាលាហជាអ្នកបង្កើតភ្លៀង ខ្យល់ ពពក ក្ដៅ រងា។ ចំពោះភ្លៀងគឺកើតដោយអំណាចនៃ«វស្សពាលាហក»ទេវតា គឺថាចង់ឲ្យភ្លៀងទីណាក៏បាន ពេលណាក៏បាន ឬក៏ទំហំប៉ុណ្ណាក៏បានតាមចិត្តរបស់ទេវតានោះ។[7] ក៏ប៉ុន្តែគួរកត់សម្គាល់ថា ពាលាហកទេវតានេះហាក់ដូចជាមានរូបរាងជាមនុស្ស ព្រោះមានរឿងព្រេងនិយាយថា ព្រះអង្គស្លៀកសំពត់ មានស្បែបង់ក អាចគង់ក្នុងឥរិយាបថអង្គុញបានផង ដែលជាបុគ្គលិកលក្ខណៈនៃមនុស្ស។*

*ទោះជាយ៉ាងណាក្តី អ្វីដែលយើងសង្កេតឃើញជារួមគឺ សេះ នាគ រាហូផ្ទុំខ្យល់ ដែលស្ថិតនៅប្រាសាទនាគព័ន្ធសឹងជាហេតុដែលទាក់ទងនឹងទឹក ជាពិសេសជាភ្នាក់ងារជួយឲ្យមានភ្លៀង។ ម៉្លោះហើយ ការរៀបចំពិធីសុំទឹកភ្លៀងនៅប្រាសាទនាគព័ន្ធមានន័យជ្រៅខ្លាំងខ្លាណាស់សម្រាប់អ្នកស្រុក។ ការប្រតិបត្តិទំនៀមបុរាណទាំងនោះបង្ហាញឲ្យឃើញនូវចំណងឥតដាច់របស់មនុស្សនិងមរតកដែលនៅជុំវិញពីជំនាន់មួយទៅជំនាន់មួយ។*

[7] Bernon, *២០២២: ១៩៦-១៩៧។*

*អត្ថបទដោយ៖ អ៊ូ គង្គា*

## ឯកសារពិគ្រោះ


- *សាម ច័ន្ទវីរៈ, ២០០៩-១០. «ពិធីសុំទឹកភ្លៀង» បណ្ដាញពត៌មានវប្បធម៌ខ្មែរ, លេខ៥, ទំ.២០-២៣*
- Bernon, Olivier de, ២០២២, *គម្ពីរត្រៃភូមិ*, ព្រះរាជាណាចក្រកម្ពុជា, https://onlinecomp.legalcouncilmef.com/tb/ (១៨ មិថុនា ២០២៦)
- Cœdès, George, 1942, *Inscriptions du Cambodge*, vol.2, Paris
- Finot, Lious, 1925, ‵Inscriptions d′Aṅkor′ *BEFEO.25*: 289-409
- Goloubew, Victor, 1927, ‵Le Cheval Balaha′ *BEFEO.27*: 223-237
- Skilling, Peter, 2003, ‵An Oṃ Maṇipadma Hūṃ Inscription from South-East Asia′ *Aseanie.11*: 13-20
- Studholme, Alexander, 2002, *The Origins of Oṃ Maṇipadme Hūṃ*, USA: State University of New York Press


AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION